# ដំណឹងបន្ថែមស្តីអំពីមេរោគ E.coli នៅក្នុងភ្ទីរ

**E.coli Toll Now Stands at 171 Outbreak Identified**
**WUML**
**9/24/06**

មកទល់នឹងថ្ងៃ សៅរ៍ ម្សិលមិញ ចំនួនមនុស្សដែលធ្លាក់ខ្លួនឈឺ ដោយសារមេរោគ E. coli ទូទាំងសហរដ្ឋ នៅតែកើនចំនួនច្រើនឡើង ជាលំដាប់ ប៉ុន្តែ អញ្ញាធរ បានបន្ធូរការតឹងតែង កុំឲ្យប្រជាជនទទួលទានបន្លែភ្ទីរ បន្តិចមកវិញដែរ។

វេជ្ជបណ្ឌិត David Acheson ដែលជាអគ្គវេជ្ជបណ្ឌិត នៃក្រសួងរដ្ឋាភិបាលទទួលបន្ទុកខាងផ្នែកចំណីអាហារនិងឧសថ, U.S. Food and Drug Administration មានប្រសាសន៍ កាលពីថ្ងៃសុក្រ ថា សាធារណៈជនប្រហែលជា អាចចាប់ទទួលទានបន្លែភ្ទីរវិញបាន ក្នុងរយៈពេលពីរ ឬបីក្រោយនេះ ពីព្រោះក្រុមហ៊ុនផលិតបន្លែភ្ទីរ កំពុងធ្វើការយ៉ាងមមាញឹក ដើម្បីដាក់បន្លែនេះលក់វិញ។

យោលទៅតាម មជ្ឈមណ្ឌលការពារនិងបង្រ្កាបជម្ងឺ, Center for Disease Control and Prevention បានឲ្យដឹងថា ចំនួនមនុស្សដែលឆ្លងមេរោគ E. coli មានដល់ទៅ 171 នាក់ នៅក្នុងរដ្ឋចំនួន 25។ ក្នុងចំណោមនោះ មានចំនួន 27 នាក់ កើតជម្ងឺខូចតម្រងនោមនិងម្នាក់ស្លាប់បាត់បង់ជីវិត។ ហើយមានស្រ្តីចំនួន 123 នាក់ និង 14នាក់ជាក្មេងអាយុតិចជាង 5 ឆ្នាំ។

កាលពីថ្ងៃព្រហស្បត្តិ៍ ទី 21 កន្លងមកនេះ, រដ្ឋ Maryland និង រដ្ឋ Tennessee បានត្រូវរាប់បញ្ចូលបន្ថែមពីលើចំនួនរដ្ឋ ឯទៀតដែលមានមនុស្សធ្លាក់ខ្លួនឈឺដោយសារមេរោគ E. coli ។ រដ្ឋទាំងនោះមាន ដូចជា៖ រដ្ឋ Arizona, California, Colorado, Connecticut, Idaho, Illinois, Indiana, Kentucky, Maine, Michigan, Minnesota, Nebraska, Nevada, New Mexico, New York, Ohio, Oregon, Pennsylvania, Utah, Virginia, Washington, Wisconsin, និង Wyoming ។ រដ្ឋ Wisconsin មានមនុស្សឈឺច្រើនជាងគេ ហើយមានទាំងម្នាក់បាត់បង់ជីវិតផង។

យោលទៅតាម មជ្ឈមណ្ឌលដដែលនេះ មេរោគ E. coli ច្រើនមាននៅក្នុងពោះវៀនគោ និងសត្វដទៃទៀត។ ហើយច្រើនមាននៅតាមសាច់ដែលចំអិនពុំបានឆ្អិនល្អ, បន្លែដូចជា បន្លែភ្ទីរ, សណ្តែកបណ្តុះនិងសាឡាត់, និងទឹកដោះគោឬទឹកផ្លែឈើឆៅ។

មេរោគ E. coli អាចធ្វើឲ្យ អ្នកជម្ងឺចាប់រាគរុះ ហើយភាគច្រើន មានឈាមក្នុងលាមកផង។ យោលទៅតាមស្ថិតិ នៅក្នុងសហរដ្ឋ មានមនុស្សធ្លាក់ខ្លួនឈឺដោយសារ មេរោគបាក់តេរីប្រភេទនេះ ចំនួនប្រហែលជា 7 ម៉ឺន 3 ពាន់ក្នុងមួយឆ្នាំៗ រួមទាំងមានមនុស្សស្លាប់ចំនួន 61 នាក់ផង។

ចំពោះពត៌មានបន្ថែមស្ដីអំពីការរាតត្បាតនៃ មេរោគ E. coli សូមមេត្តាអានវិបសៃរបស់ក្រសួងរដ្ឋាភិបាលផ្នែកចំណីអាហារនិងឧសថ ដែលហៅថា U.S. Food and Drug Administration ដែលមានអាស័យដ្ឋាន [www.fda..gov](http://www.fda..gov) ឬទូរស័ព្ទលេខ 1-888-463-6332 ឬ មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ, Center for Disease Control and Prevention ដែលមានអាស័យដ្ឋា [www.cdc.gov](http://www.cdc.gov) ។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីសារពត៌មាន Healthfinder នៃ ក្រសួងសុខភាព និងមនុស្សធម៌ U.S. Department of Health and Human Services។ ដោយ មណ្ឌលមេត្តា សុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*

http://www.healthfinder.gov/news/newsstory.asp?Docid=535120